ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អ អ ក
EAC
អាជ្ញាធរអគ្គិសនីកម្ពុជា
លេខ ០២៦ សណ/២០ អអក

ថ្ងៃ សុក្រ ៧កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២០

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈ លើគម្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទដែលទិញអគ្គិសនីពីបណ្តាញបញ្ជូនរង និងបណ្តាញចែកចាយមានប្រភពពីបណ្តាញជាតិរបស់អ្នកកាន់អាជ្ញាបណ្ណឯកជន សម្រាប់ឆ្នាំ២០២០

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូន **អ្នកប្រើប្រាស់អគ្គិសនី** ដែលឋិតនៅក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់អ្នកកាន់អាជ្ញាបណ្ណឯកជនចំនួន ៣២៤ តំបន់ ដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ មាននៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយ ។ ឲ្យបានជ្រាបថា ពេលនេះ ក្រសួងរ៉ែ និងថាមពល បានចេញប្រកាសលេខ០០៤០ រថ.អរថ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យអនុវត្តផែនការបន្ថយថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ និងផែនការកែទម្រង់ការបង់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១ ។ ដូច្នេះ យោងតាមប្រកាសថ្មីនេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទដែលទិញអគ្គិសនីពីបណ្តាញបញ្ជូនរង និងបណ្តាញចែកចាយមានប្រភពពីបណ្តាញជាតិរបស់អ្នកកាន់អាជ្ញាបណ្ណឯកជន សម្រាប់ឆ្នាំ២០២០ ដែលត្រូវអនុវត្តចំពោះថាមពលប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ តទៅ តាមប្រភេទអ្នកប្រើប្រាស់ និងអត្រាថ្លៃលក់អគ្គិសនី ដូចខាងក្រោម៖

| ប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌទិញ | ឯកតា | អត្រាថ្លៃ ឆ្នាំ២០១៩ | អត្រាថ្លៃថ្មី ឆ្នាំ២០២០ |
|---|---|---|---|
| **១. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ៖** | | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1470 | 0.1370 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | គ្មាន | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន | $/kWh | 0.1750 | 0.1300 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច | $/kWh | 0.1200 | 0.1100 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 10.00 | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1200 | 0.1300 |

| | | | |
|---|---|---|---|
| **២. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ៖** | | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1590 | 0.1580 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | គ្មាន | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន | $/kWh | 0.1750 | 0.1500 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច | $/kWh | 0.1200 | 0.1240 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 10.00 | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1200 | 0.1500 |
| **៣. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន) ៖** | | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1529 | 0.14248 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | គ្មាន | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន | $/kWh | គ្មាន | 0.13520 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច | $/kWh | គ្មាន | 0.11440 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 10.00 | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1250 | 0.1352 |
| **ចំពោះអ្នកសុំឲ្យអ្នកផ្គត់ផ្គង់វិនិយោគត្រង់ស្វូឲ្យខ្លួន ៖** | | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1609 | 0.15048 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | គ្មាន | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន | $/kWh | គ្មាន | 0.14320 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច | $/kWh | គ្មាន | 0.12240 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 11.38 | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1250 | 0.1432 |
| **៤. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន) ៖** | | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1654 | 0.16432 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | គ្មាន | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន | $/kWh | គ្មាន | 0.15600 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច | $/kWh | គ្មាន | 0.12896 |

| | | | |
|---|---|---|---|
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 10.00 | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1250 | 0.1560 |
| **ចំពោះអ្នកសុំឲ្យអ្នកផ្គត់ផ្គង់វិនិយោគត្រង់ស្វូឲ្យខ្លួន ៖** | | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1734 | 0.17232 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | គ្មាន | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន | $/kWh | គ្មាន | 0.16400 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច | $/kWh | គ្មាន | 0.13696 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 11.38 | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1250 | 0.1640 |
| **៥. អ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្ដាញចែកចាយ LV ៖** | | | |
| ៥.១ លំនៅដ្ឋានទិញពីខ្សែបណ្ដាញចែកចាយ LV ៖ | | | |
| ➢ អ្នកប្រើពី ១ ដល់ ១០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៛/kWh | 380 | 380 |
| ➢ អ្នកប្រើពី ១១ ដល់ ៥០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៛/kWh | 480 | 480 |
| ➢ អ្នកប្រើពី ៥១ ដល់ ២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៛/kWh | 610 | 610 |
| ➢ អ្នកប្រើលើសពី ២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៛/kWh | 740 | 730 |
| ៥.២ អ្នកប្រើប្រាស់ប្រភេទផ្សេងទៀត ក្រៅពីលំនៅដ្ឋាន | ៛/kWh | 740 | 730 |
| ៥.៣ អ្នកបូមទឹកធ្វើកសិកម្មពេលយប់ពី៩យប់ដល់៧ព្រឹក | ៛/kWh | 480 | 480 |
| ៥.៤ សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព នៅជនបទ | ៛/kWh | 610 | 610 |

**សំគាល់៖** ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម សម្រាប់អ្នកប្រើប្រាស់ធុនធំ ភ្ជាប់លើតង់ស្យុងមធ្យម (MV) និងធុនមធ្យម នឹងត្រូវអស់សុពលភាពអនុវត្តត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ។ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ "បញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" នឹងត្រូវអនុវត្តចំពោះអ្នកប្រើប្រាស់ទាំងនោះ ដោយស្វ័យប្រវត្តិ ។

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសូមដាក់ "ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី" ថ្មីនេះ ពិគ្រោះយោបល់ជាសាធារណៈ ជាមួយក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់អគ្គិសនី នៅក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីឯកជនទាំង ៣២៤ តំបន់ ដូចបញ្ជាក់ក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ។ ក្រោយថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ "ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី" ថ្មីនេះ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា

មានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដើម្បីរក្សាបានយុត្តិធម៌រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកផ្គត់ផ្គង់ផង ។ ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ អាជ្ញាធរអគ្គិសនីកម្ពុជា ទីស្នាក់ការផ្គត់ផ្គង់អគ្គិសនីឯកជន សាលារាជធានី-ខេត្តទាំង ២៤ សាលាស្រុក-ខណ្ឌ និងសាលាឃុំ-សង្កាត់ សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ មានក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ដល់អាជ្ញាធរអគ្គិសនីកម្ពុជា លើ "ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី" ថ្មីនេះ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**យឹម ឋិសិដ្ឋ**